ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 25 / 08 / 2009
ម៉ោង (Time/Heure) : 10:00
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: [signature]

ភ្នំពេញ ថ្ងៃទី ខែសីហា ២០០៩
ជូនចំពោះសហចៅក្រមស៊ើបអង្កេត
លោក យូ ប៊ុនឡេង
លោក Marcel LEMONDE
ភ្នំពេញ កម្ពុជា

ឯកសារស៊ើបអង្កេតលេខ: ០០២/១៩-០៩-២០០៧

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 18 / 12 / 2009
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Uch Arun

**កម្មវត្ថុ:** សេចក្តីប្រកាសគាំទ្រពាក្យសុំឱ្យបំពេញកិច្ចស៊ើបសួរទី៣ របស់ លោក អៀង សារី-វិធាន៥៥-១០

លោក សហចៅក្រមស៊ើបអង្កេត

តាមបណ្តឹងចុះថ្ងៃទី២១ ឧសភា ឆ្នាំ២០០៩ សហមេធាវីរបស់ លោក អៀង សារី ដែលជាសហភាគីរបស់យើងបានប្តឹងមកលោក ក្នុងបំណងសុំឱ្យបំភ្លឺនីតិវិធីនៃការស៊ើបសួរដែលការិយាល័យរបស់លោកបានធ្វើជិតពីរឆ្នាំមកហើយ[1]។ ពាក្យបណ្តឹងសុំឱ្យបំពេញកិច្ចស៊ើបសួរនេះបានទទួលការគាំទ្រយ៉ាងឆាប់រហ័សអំពីសំណាក់ក្រុមការពារក្តីរបស់លោក នួន ជា[2]។ ដោយហេតុថាយើងមានការព្រួយបារម្ភពាក់ព័ន្ធនឹងរបៀបស៊ើបអង្កេតដែលត្រូវបានធ្វើកន្លងមកដែរ យើងសូមប្រកាសគាំទ្រនូវគ្រប់មធ្យោបាយនិងសំណូមពររបស់ពួកគាត់។

ក្នុងឱកាសនេះ យើងខ្ញុំសូមបញ្ជាក់ថាគោលបំណងនៃបណ្តឹងនេះមិនមែនចង់យកតួនាទីរបស់ចៅក្រមស៊ើបអង្កេតមកចោទជាបញ្ហានោះទេ ក៏ប៉ុន្តែចង់ធ្វើការផ្ទៀងផ្ទាត់ភាពត្រឹមត្រូវនៃការស៊ើបសួរដូចដែលការិយាល័យចៅក្រមស៊ើបអង្កេតបានធ្វើមកសម្រាប់សំណុំរឿង ០០២។ យើងមានមនសការច្បាស់ណាស់ថាតួនាទីរបស់សហចៅក្រមស៊ើបអង្កេត គឺដឹកនាំនីតិវិធីនៃការស៊ើបសួរ ហើយ ដូច លោក Faustin Hélie បានរំលឹកថាចៅក្រមស៊ើបអង្កេតក៏ជា "អាជ្ញាកណ្តាលនៃនីតិវិធី" ផងដែរ។ ក៏ប៉ុន្តែយើងក៏ដឹងផងដែរថាគ្មានចៅក្រមណាពុំមានការផ្តោះផ្តោយនោះទេ ហើយ កាលណា មានបន្ទុកកាន់តែ

---

[1] ពាក្យសុំឱ្យបំពេញកិច្ចស៊ើបសួរទី៣ដែលស្នើឡើងដោយ លោក អៀង សារី, ២១ ឧសភា ២០០៩, *ឯកសារតុលាការ D171*

[2] Notice of joinder to Ieng Sarys's third for investigative action, 09 juin 2009, *Document judiciaire D171/2*

ធ្ងន់ វាធ្វើឱ្យកាន់តែលំបាកនឹងបំភ្លេច ហើយ កាលណាគេខំប្រឹងស្វែងរកពិរុទ្ធភាពខ្លាំងពេក ជារឿយៗ គេអាចប្រាសចាកពីសច្ចភាព ពីព្រោះការស៊ើបសួរអង្កេតដើម្បីដាក់បន្ទុក និងដោះបន្ទុកនេះ បើនិយាយឱ្យចំទៅគឺមានន័យថា "ប្រឆាំងនឹងទំនោរនៃអារម្មណ៍ដែលអស់សង្ឃឹមអំពីភាពផ្តេសផ្តាសមកធ្លាក់ក្នុងភាពសកម្មចង់តែដាក់បន្ទុក ដល់ទីបញ្ចប់លើភាពផ្តេសផ្តាសនេះ[3]"។

ទោះបីជានៅក្នុងប្រព័ន្ធច្បាប់បារាំងចាស់ គេយល់ថាមានតែការស៊ើបអង្កេតដែលមិនឱ្យជនត្រូវចោទដឹងរឿងនោះទេដែលអាចផ្តល់លទ្ធផលល្អបានក៏ដោយ ក៏ប៉ុន្តែ សព្វថ្ងៃនេះ ច្បាប់បានកំណត់ ថាការរក្សារអាថ៌កំបាំងនៃការស៊ើបសួរមិនត្រូវអនុវត្តលើជនត្រូវចោទទៀតទេ ហើយតម្លាភាពគឺជាលក្ខខ័ណ្ឌចាំបាច់នៃសមភាព។ ក្នុងស្មារតីនេះ ការផ្តល់ព័ត៌មានដល់ជនត្រូវចោទអំពីយុទ្ធសាស្ត្រវិធីសាស្ត្រ និង អំពីច្បាប់អនុវត្តដើម្បីទទួលបានការពិតពីការស៊ើបអង្កេត គឺជាការធានាកុំឱ្យមានភាពអត្តនោម័ត ចំពោះជនត្រូវចោទក៏ដូចជាចំពោះចៅក្រមខ្លួនឯងផ្ទាល់ដែរ។

អាស្រ័យហេតុដូច្នេះ យើងសូមចូលរួមចំណែកជាមួយសហភាតាការពារក្តី ដើម្បីប្តឹងសុំឱ្យលោកសហចៅក្រមស៊ើបអង្កេតផ្តល់មកយើងនូវព័ត៌មានដែលមានចែងនៅកថាខណ្ឌ ១៤ ២០ ២៦ ២៨ ៣៦ និង ៤២ នៃពាក្យបណ្តឹងសុំឱ្យបំពេញកិច្ចស៊ើបសួរទី៣ របស់ លោក អៀង សារី។

សូមលោក សហចៅក្រមទទួលការគោរពដ៏ខ្ពង់ខ្ពស់អំពីយើងខ្ញុំ។

សហមេធាវីនៃអង្គភាពគាំពារការការពារក្តី

មេធាវី ស សូភ័ត                                        មេធាវី Jacques Vergès

[3] Citattion tirée du traité de l'instruction criminelle, Chapitre IV "Attibutions génerales du Juge d'instruction'' Faustin Hélie, p. 257